# កម្ពុជា៖ "ការយាយីរំខានតុលាការ ដើម្បីគោលបំណងនយោបាយត្រូវតែបញ្ឈប់" - អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានមានប្រសាសន៍

ទីក្រុងហ្សឺណែវ (១៨ វិច្ឆិកា ២០១៤) - អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី នៅថ្ងៃនេះបានជំរុញឱ្យរដ្ឋាភិបាលកម្ពុជាគោរពច្បាប់និងគោលការណ៍ឯករាជ្យភាពរបស់តុលាការ។ នៅពេលជាមួយគ្នានេះដែរ លោកបានអំពាវនាវឲ្យស្ថាប័នតុលាការនៃប្រទេសនេះឲ្យអនុវត្តយ៉ាងមឹងម៉ាត់នូវអំណាចតុលាការ ឯករាជ្យពីឥទ្ធិពលខាងក្រៅ។

"ខ្ញុំមានការខកចិត្ត ដោយឃើញតុលាការ ត្រូវបានគេប្រើប្រាស់ម្តងហើយ ម្តងទៀតជាឧបករណ៍របស់អង្គនីតិប្រតិបត្តិ" លោក ស៊ូប៊ែឌី បានមានប្រសាសន៍ ប្រតិកម្មតបទៅនឹងការចាប់ខ្លួននិងការផ្តន្ទាទោសជាបន្តបន្ទាប់នូវសកម្មជនដីធ្លី និងសមាជិកគណបក្សប្រឆាំង។

នៅសប្តាហ៍កន្លងមកនេះ សកម្មជនដប់មួយនាក់ ត្រូវបានចាប់ខ្លួន ចោទប្រកាន់ និងផ្តន្ទាទោសភ្លាមៗក្នុងសវនាការមហាជន ដោយសារការចូលរួមក្នុងការតវ៉ាអហិង្សា។ "ចាប់តាំងពីខ្ញុំបានកាន់អាណត្តិជាអ្នករាយការណ៍ពិសេស ខ្ញុំបានឃើញករណីនេះកើតមានរាប់មិនអស់នៅកម្ពុជា" អ្នកជំនាញសិទ្ធិមនុស្សបានគូសបញ្ជាក់ដូច្នេះ។

"កង្វះឯករាជ្យភាពតុលាការ គឺជាឧបសគ្គដ៏ធំមួយ ក្នុងចំណោមឧបសគ្គធំៗជាច្រើនទៀតក្នុងការទទួលបានសង្គមមួយយុត្តិធម៌ និងមានការចូលរួម ដែលប្រជាជនកម្ពុជាប្រាថ្នាចង់បាន។ ទង្វើកាលពីពេលថ្មីៗនេះ របស់តុលាការបង្ហាញជាថ្មីម្តងទៀតពីតម្រូវការឲ្យមានប្រព័ន្ធតុលាការឯករាជ្យនៅកម្ពុជា" លោកស៊ូប៊ែឌី បានសង្កត់ធ្ងន់ដូច្នេះ។

សមាជិកពីរនាក់របស់គណបក្សប្រឆាំង រាប់ទាំង មៀច សុវណ្ណារ៉ាដែលគាត់ជាប្រធាននាយកដ្ឋានព័ត៌មាននៃគណបក្សសង្គ្រោះជាតិ(CNRP) ត្រូវបានចាប់ខ្លួនផងដែរពីបទចោទប្រកាន់ "ការបះបោរ" ក្នុងការតវ៉ានៅទីលានប្រជាធិបតេយ្យ នៅថ្ងៃទី១៥ ខែកក្កដា។ រហូតមកទល់ថ្ងៃនេះ មានសមាជិក និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ចំនួន ១៧ នាក់ហើយត្រូវបានចោទប្រកាន់ ចាប់តាំងពីខែកក្កដា ពាក់ព័ន្ធនឹងការធ្វើបាតុកម្ម កាលពីថ្ងៃទី១៥ ខែកក្កដា កន្លងទៅ។

"អ្នកដែលស្វែងរកការអនុវត្តសេរីភាពជាមូលដ្ឋាន អាចត្រូវបានគេចាប់ខ្លួន ចោទប្រកាន់ និងផ្តន្ទាទោសផ្អែកលើភស្តុតាងតិចតួច ឬគ្មានទាល់តែសោះ។ ចំពោះករណីដូចនេះ យុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការដែលមានសំណុំរឿងកកស្ទះខ្លាំង បែរទៅជាអាចត្រូវបានចាត់ការយ៉ាងឆាប់រហ័សគួរឱ្យកត់សំគាល់ទៅវិញ" នេះបើតាមការកត់សំគាល់របស់លោកស៊ូប៊ែឌី ។ "តាមពិតទៅ ខ្ញុំសោកស្តាយដែលថាពេលវេលាដែលបុគ្គលទាំងនេះ ត្រូវបានចាប់ខ្លួន ចោទប្រកាន់ និងការផ្តន្ទាទោស

ទំនងជាត្រូវបានគណនាច្បាស់លាស់”។

អ្នកជំនាញរូបនេះ បានរំលឹកថាច្បាប់កម្ពុជា តម្រូវថា ការវិនិច្ឆ័យរបស់តុលាការ ត្រូវបានផ្អែកតែលើភស្តុតាងប៉ុណ្ណោះ។ “នៅពេលដែលភស្តុតាងមិនបង្ហាញពីពិរុទ្ធភាព វាគឺជាកាតព្វកិច្ចរបស់តុលាការក្នុងការដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញ” លោកបានបញ្ជាក់ដូច្នេះ។

“ការចាប់ខ្លួន ឬការឃុំខ្លួនជាទោសទណ្ឌសម្រាប់ការអនុវត្តសិទ្ធិស្របច្បាប់ ដែលបានធានាការពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ រាប់ទាំងសេរីភាពក្នុងការជួបប្រជុំ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការបញ្ចេញមតិ ក៏ដូចជាសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ គឺជាទង្វើបំពាន” អ្នករាយការណ៍ ពិសេស បានគូសបញ្ជាក់ដូច្នេះ។

“ជំនឿទុកចិត្តរបស់សាធារណៈជន លើស្ថាប័ននេះ ធ្វើឡើងដើម្បីរក្សាសន្តិភាព និងសណ្តាប់ធ្នាប់នឹងមិនត្រូវបានស្តារឡើងវិញដោយការបន្ថែមទៅក្នុងបញ្ជីករណីរំលោភបំពានដែលជាបញ្ហានិទណ្ឌភាពនោះទេតែផ្ទុយទៅវិញ វាមានតែផុសឡើង នៅពេលដែលនិទណ្ឌភាពត្រូវបានដោះស្រាយ នេះបើតាមការបញ្ជាក់បន្ថែមរបស់អ្នកជំនាញអង្គការសហប្រជាជាតិ ដោយរំលឹកថា មិនមានកម្លាំងសន្តិសុខណាម្នាក់ ដែលបានធ្វើ ឱ្យមនុស្សរងរបួស និងស្លាប់ច្រើននាក់ កាលពីឆ្នាំកន្លងទៅ រាប់ទាំងនៅក្នុងព្រឹត្តិការណ៍ថ្ងៃទី១៥ ខែកក្កដា ត្រូវបានចាប់ឲ្យទទួលខុសត្រូវនៅឡើយទេ។

លោក ស៊ូបេឌី បានគូសបញ្ជាក់ពីតម្រូវការបន្តធ្វើដំណើរលើផ្លូវឆ្ពោះទៅរកការធ្វើកំណែទម្រង់។ បើតាមទស្សនៈរបស់គាត់ “ការងាកចេញពីបញ្ហាសំខាន់នៃការធ្វើកែទម្រង់ប្រព័ន្ធតុលាការ ការបោះឆ្នោត សភា និងវិស័យសាធារណៈ មានតែការបង្ហាញពីតម្រូវការរបស់វាប៉ុណ្ណោះ មិនមែនបញ្ច្រាសនោះទេ។ អាជ្ញាធរមិនត្រូវបង់បោះចោលការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបន្តធ្វើកំណែទម្រង់ឡើយ”។

អាណត្តិរបស់អ្នករាយការណ៍ពិសេស ត្រូវបានបន្តសម្រាប់រយៈពេលពីរឆ្នាំបន្ថែមទៀត ក្នុងខែកញ្ញាឆ្នាំ២០១៣ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ លោក ស៊ូប៊ែឌី នឹងលាឈប់ពីតំណែងនៅពេលដែលគាត់ដល់អាណត្តិប្រាំមួយឆ្នាំពេញ ក្នុងខែមីនា ឆ្នាំ២០១៥។ បេសកកម្មបន្ទាប់ និងជាបេសកកម្មចុងក្រោយបំផុតរបស់លោក មកកាន់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងធ្វើនៅក្នុងខែមករា ឆ្នាំ២០១៥ លទ្ធផលនៃដំណើរបេសកកម្មនេះ នឹងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយអ្នកស្នងតំណែងរបស់ គាត់។

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបេឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន*

*លោកជាសាស្ត្រាចារ្យនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូប នៃគណៈមេធាវីមីឌីលថឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ាននៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្ដីអាស៊ាននៃច្បាប់អន្តរជាតិ ដោយការិយាល័យព័ត៌មាននៃសាកលវិទ្យាល័យខេមប្រីដជ៍។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖*

*[http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx](http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx)*

*ដើម្បីអានរបាយការណ៍ចុងក្រោយបំផុតរបស់អ្នករាយការណ៍ពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប (A/HRC/27/70) សូមចូលទៅកាន់គេហទំព័រ៖*

*[http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session27/Pages/ListReports.aspx](http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session27/Pages/ListReports.aspx)*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*

*[http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx](http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx)*

*រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក កញ្ញា Olga Nakajo តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉ែល onakajo@ohchr.org) ឬសរសេរមកកាន់ srcambodia@ohchr.org*

*ដើម្បីសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់អ.ស.ប សូមទាក់ទងមក សាប៉ៀ សីលាយ៉ា សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** [https://www.facebook.com/unitednationshumanrights](https://www.facebook.com/unitednationshumanrights)
**ទ្វីតធឺ៖** [http://twitter.com/UNrightswire](http://twitter.com/UNrightswire)
**ហ្គោហ្គលៈ Google+** gplus.to/unitednationshumanrights
**យូធូប៖** [http://www.youtube.com/UNOHCHR](http://www.youtube.com/UNOHCHR)
**និទានរឿង៖** [http://storify.com/UNrightswire](http://storify.com/UNrightswire)
**ឆែកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖** [http://uhri.ohchr.org/en](http://uhri.ohchr.org/en)